**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២១៥ . អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត នៅថ្នាក់ក្រោមជាតិ-ថ្នាក់ជាតិ ឆ្នាំ២០១១-២០១៤

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០២០ ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- ផ្អែកតាមផែនការអន្តរស្ថាប័ន លេខ ០១៤ ផ.ក/១១ ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០១១ ស្តីពីកិច្ចការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សម្រាប់ការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ-ថ្នាក់ជាតិឆ្នាំ ២០១១-២០១៤ ក្រសួងមហាផ្ទៃ-ការពារជាតិ និង គ.ជ.ប

- យោងតាមការចាំបាច់ ។

# សម្រេច

**មាត្រា ១.-** ត្រូវបានបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត នៅថ្នាក់ក្រោមជាតិ-ថ្នាក់ជាតិឆ្នាំ ២០១១-២០១៤ អក្សរកាត់ " **គ.ស.អ** " ដែលមានសមាសភាព ដូចតទៅ :

| | | | |
|---|---|---|---|
| ១- ឯកឧត្ដម | **ស ខេង** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| ២- ឯកឧត្ដម | **ទៀ បាញ់** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ | អនុប្រធាន |
| ៣- ឯកឧត្ដម | **គាត ឈន់** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤- ឯកឧត្ដម | **ឯម សំអាន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៥- ឯកឧត្ដម | **ចាយ សាំងយុន** | រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ៦- ឯកឧត្ដម នាយឧត្ដមសេនីយ៍ | **ម៉ុល សារឿន** | អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ | សមាជិក |
| ៧- ឯកឧត្ដម នាយឧត្ដមសេនីយ៍ | **នេត សាវឿន** | អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ៨- ឯកឧត្ដម នាយឧត្ដមសេនីយ៍ | **សៅ សុខា** | អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៩- អភិបាលនៃគណៈអភិបាល និងជាប្រធានគណៈបញ្ជាការឯកភាពគ្រប់រាជធានី ខេត្ត | | | សមាជិក |

**មាត្រា ២.-** គ.ស.អ មានភារកិច្ចទទួលខុសត្រូវ ដូចខាងក្រោម :

- សហការសម្របសម្រួល ជាមួយនឹងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប ) លើការងារសន្តិសុខទូទៅសម្រាប់ការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ-ថ្នាក់ជាតិ ដែលរួមមាន : ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១ ការបោះឆ្នោតព្រឹទ្ធសភានីតិកាលទី ៣ ការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី ៣ ការបោះឆ្នោតតំណាងរាស្ត្រអាណត្តិទី ៥ និងការបោះឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌអាណត្តិទី ២ តាមនីតិកាល និងអាណត្តិនីមួយៗ ចាប់ផ្ដើមពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៤ ។
- ចាត់តាំងកម្លាំងអនុវត្តច្បាប់ ពិសេសគណៈអភិបាល ឬគណៈបញ្ជាការឯកភាពគ្រប់រាជធានី ខេត្ត និងកងនគរបាលជាតិ ឬ/និងកងរាជអាវុធហត្ថ ឬ/និងកងយោធពលខេមរភូមិន្ទ ឱ្យបំពេញភារកិច្ចជាភ្នាក់ងារសន្តិសុខបោះឆ្នោត ដោយសហការឱ្យបានជិតស្និទ្ធជាមួយនឹង គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីធានាឱ្យគ្រប់ដំណើរការបោះឆ្នោតទៅថ្នាក់ក្រោមជាតិ-ថ្នាក់ជាតិនីមួយៗប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ គ្មានការបំភិតបំភ័យ ការគំរាមកំហែង និងអំពើហិង្សា ។
- ផ្សព្វផ្សាយព័ត៌មាន គោលការណ៍ណែនាំ និងវិធានការផ្សេងៗ ស្ដីពីការងារសន្តិសុខបោះឆ្នោត ទៅដល់គ្រប់យន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតទាំងអស់ ដើម្បីជ្រាប និងសហការអនុវត្ត ។
- ប្រមូលផ្ដុំព័ត៌មាន ឬពាក្យប្ដឹងទាក់ទងសន្តិសុខបោះឆ្នោត ពីបណ្ដាស្ថាប័ន ឬអង្គភាពពាក់ព័ន្ធ និងគណៈបញ្ជាការឯកភាពគ្រប់លំដាប់ថ្នាក់នៃរាជធានី ខេត្ត ដើម្បីពិនិត្យដោះស្រាយស្របតាមនីតិវិធី ។

- ពិនិត្យចាត់វិធានការ ប្រមូលផ្តុំ ចាត់តាំងកម្លាំងនគរបាលជាតិ ឬ/និងកងរាជអាវុធហត្ថ ឬ/ និងកងយោធពលខេមរភូមិន្ទ ដោយប្រើប្រាស់សម្ភារៈ ឧបករណ៍ និងមធ្យោបាយគ្រប់ប្រភេទ របស់បណ្តាស្ថាប័ន និងអង្គភាពនីមួយៗផ្ទាល់ដែលមានស្រាប់ ដើម្បីរួមចំណែកអនុវត្តកិច្ចប្រតិបត្តិការការពារ សន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ ឱ្យមានប្រសិទ្ធភាពខ្ពស់សម្រាប់គ្រប់ដំណើរការ នៃការរៀបចំការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ-ថ្នាក់ជាតិ ទាំងមូល ។

**មាត្រា ៣.-** ផ្អែកតាមផែនការអន្តរស្ថាប័នលេខ ០១៤ ផ.ក/១១ ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០១១ ស្តីពីកិច្ចការការពារសន្តិសុខសម្រាប់ការបោះឆ្នោត រវាងក្រសួងមហាផ្ទៃ-ការពារជាតិ និង គ.ជ.ប ប្រធាន គ.ស.អ ត្រូវពិនិត្យរៀបចំគម្រោងថវិកាបំប៉នដល់កម្លាំងការពារសន្តិសុខ និងថវិកាចំណាយលើការផ្គត់ផ្គង់ប្រេងឥន្ធនៈ សម្ភារៈឧបករណ៍ ឬមធ្យោបាយប្រើប្រាស់តាមការចាំបាច់ រួចស្នើសុំការអនុម័តពីរាជរដ្ឋាភិបាល ។

**មាត្រា ៤.-** គ.ស.អ មានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយ ជាជំនួយការការងារ និងមានសិទ្ធិប្រើប្រាស់ថវិកា និងត្រា របស់គណៈរដ្ឋមន្ត្រីសម្រាប់រាល់កិច្ចការក្នុងវិស័យរដ្ឋបាល ឬលិខិតស្នាមផ្លូវការផ្សេងៗរបស់ខ្លួន ។

**មាត្រា ៥.-** គ.ស.អ គឺជាសេនាធិការផ្ទាល់ជូនរាជរដ្ឋាភិបាល មានភារកិច្ចត្រូវរាយការណ៍ជាប្រចាំ អំពីស្ថានការណ៍សន្តិសុខបោះឆ្នោតទូទៅ និងការរៀបចំកម្លាំងភ្នាក់ងារសន្តិសុខបោះឆ្នោត សម្រាប់គ្រប់សម័យកាលនៃដំណើរការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ-ថ្នាក់ជាតិនីមួយៗ ។

**មាត្រា ៦.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋាន គ.ជ.ប
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ
- អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- សាលារាជធានី ខេត្ត ទាំង ២៤
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ